# សហគមន៍ភូមិផោន



## ដីយើង អនាគតយើង

# សហគមន៍ភូមិដោនកំពុងតែគិតផ្តួលអនាគតរបស់ខ្លួន

សហគមន៍ភូមិដោនបានប្រាប់ថា ពួកគាត់គួរតែអាច នឹងមានលុយសំរាប់ការអភិវឌ្ឍន៍ដោយការលក់ដី ធ្លីរបស់ខ្លួន។ ដូច្នេះពួកគាត់រៀបចំការប្រជុំមួយ ហើយពួកគាត់ គិតអំពីតំរូវការអ្វីខ្លះ ដែលពួកគាត់ត្រូវការដើម្បីអភិវឌ្ឍន៍ ភូមិរបស់ពួកគេ។



តំរូវការរបស់គាត់រួមមានៈ

- សាលាប្រជុំភូមិ
- សេវាកម្មបំរើផ្នែកសុខភាព
- ការអប់រំ
- ថវិកាសំរាប់ឧបត្ថម្ភដល់គ្រួសារក្រីក្រ
- វគ្គបណ្តុះបណ្តាលស្តីអំពី ជំនាញផ្នែកដាំដុះ និង ការលក់ដូរ

ពួកគាត់ក៏បានគិតផងដែរអំពីវិធីសាស្ត្រដែលអាចនឹងរកលុយបានដើម្បីតំរូវការខាងលើនេះហើយធ្វើអោយជីវភាពប្រសើរឡើង។ មានតែវិធីមួយគត់គឺ លក់ ដី ប៉ុន្តែទន្ទឹងនឹងនេះពួកគាត់ក៏បានរិះរកនូវវិធីសាស្ត្រផ្សេងៗទៀតដែរ។ នៅពេលដែលពួកគេគិតអំពី ការលក់ដីភ្លាមនោះ ពួកគេក៏ដឹងដែរថាប្រសិនបើលក់ដីនោះ ពួកគេអាចរកប្រាក់ចំណូលបានតែម្តងនោះទេ។ លើសពីនោះទៀតពួកគេក៏បានគិតដែរថា



ការបើកជំហរលក់ដីទៅអ្នក
ខាងក្រៅនោះវាអាចដឹង
មានផលអវិជ្ជមានយ៉ាងច្រើន
ដល់សហគមន៍។

ដូច្នេះពួកគាត់បានរកគ្រប់វិធីក្នុងការប្រើប្រាស់ដីរបស់
ខ្លួនដើម្បីរកលុយទិញរបស់ដែលពួកគាត់ចង់បាននោះ។

គាត់គិតអំពីការជួលដីរបស់ខ្លួនទៅអោយអ្នកខាងក្រៅ ហើយគាត់ដឹងថាអ្នកខាងក្រៅអាចបង់ចំណូលខ្លះៗដើម្បីប្រើប្រាស់ដីសហគមន៍ គាត់ដឹងផងដែរថា ប្រសិនបើគាត់ធ្វើកិច្ចសន្យាជួលដីរបស់ខ្លួនដល់អ្នកខាងក្រៅគាត់នឹងអាចប្រឈមមុខនឹងគ្រោះថ្នាក់ដោយមិនអាចយកដីមកវិញបានឡើយ ។

មិនតែប៉ុណ្ណោះគាត់នឹងប្រឈមមុខពីផល

ប៉ះពាល់ផ្នែកវប្បធម៌ ដែលហូរចូលពីអ្នក

ខាងក្រៅ ។

ដូច្នេះ គាត់គិតរកវិធីសាស្រ្តផ្សេងៗទៀត

ក្នុងការប្រើប្រាស់ដីរបស់ខ្លួនដើម្បីរក

ប្រាក់ចំណូលផ្គត់ផ្គង់តំរូវការផ្សេងៗ

ដែលខ្លួនត្រូវការ ។





មានតែវិធីមួយគឺការធ្វើចំការដោយខ្លួនឯងផ្ទាល់ លក់ផលិតផលទាំងឡាយ ហើយធ្វើការផ្តល់វិភាគទាន សំរាប់មូនិធិសហគមន៍។



ពួកគាត់ក៏គិតថា គាត់អាចធ្វើការដាំឈើជាសហគមន៍ផងដែរ ។ ក្នុងមធ្យោបាយនោះ សហគមន៍ទាំងមូលនឹងធ្វើការផ្តល់ជូននូវតំលៃកំលាំងពលកម្មតិចតួច ។ ហើយប្រាក់ចំណូលពីការប្រមូលផលនោះនឹងត្រូវបានប្រើប្រាស់ ំរាប់បំរើឱ្យផលប្រយោជន៍សហគមន៍ ។



បន្ទាប់មក សហគមន៏បានគិតថា ពួកគាត់មានធនធានផ្សេងៗជាច្រើនទៀតដែលពួកគាត់អាចប្រើប្រាស់បាន។ ប្រសិនបើពួកគាត់ការពារដីធ្លី និងធនធានធម្មជាតិរបស់ពួកគាត់បានគង់វង្ស ពួកគាត់អាចប្រមូលអនុផលផ្សេងៗមកពីព្រៃឈើសំរាប់ជាការលក់ដូរ។

ជាឧទាហរណ៏មួយស្រាប់ ពួកគាត់អាចធ្វើការប្រមូល និងដកហូតផ្តៅដើម្បីលក់ដូរ។

សហគមន៍គួរមើលឃើញផងដែរនូវដីធ្លី ដីចំការ កសិកម្ម ព្រៃឈើ ការអភិវឌ្ឍន៍សហគមន៍ និងវប្បធម៌របស់ពួកគេ គឺជាទ្រព្យសម្បត្តិទាំងឡាយដែលត្រូវបានគេចាប់អារម្មណ៍។

ដូច្នេះពួកគាត់ថា ពួកគាត់គួរតែរៀនអំពីរបៀបគ្រប់គ្រងវិស័យទេសចរណ៍ ដោយហេតុថា គេអាចរកបានប្រាក់ចំណូលខ្លះៗពីវិស័យនេះ។



ពួកគេក៏បានគិតផងដែរថាពួកគាត់គួតែត្រូវ រក្សាទុកដីរបស់ខ្លួន ហើយពួកគាត់អាចដាំដុះបន្លែបង្កាផ្សេងៗដោយមិនមានការដាក់ជីគីមី និងដំណាំមានតំលៃខ្ពស់ ពួកគាត់បានគិតផងដែរថាការដាំដំណាំសំរាប់ជាម្ហូបអាហារ វាគ្រប់គ្រាន់ដែលអាចធ្វើឱ្យពួកគាត់ពេញចិត្តហើយ ។





សហគមន៏ចាប់ផ្តើមមានជំនឿថា ដោយការការពារ នូវការចិញ្ចឹមជីវិតជាប្រពៃណី និងវប្បធម៏រស់នៅរបស់ពួកគេ អាចធ្វើអោយពួកគេដាំនូវដំណាំបង្កើនសុខភាព ហើយប្រាក់ចំណូលអាចធ្វើការចាយវាយសំរាប់តែសេវាកម្មផ្សេងៗ ដែលត្រូវការបំផុត និងការសិក្សាអប់រំ ។



ជាចុងក្រោយ អ្នកភូមិដោន មានការរីករាយយ៉ាងខ្លាំងពីការពិចារណាលើអនាគតរបស់ពួកគេផ្ទាល់ ។ វាមានសារសំខាន់ណាស់ដែលគួរចងចាំថា មានជំរើសច្រើនក្នុងការអភិវឌ្ឍន៍ ។ សហគមន៍ភូមិដោន បានសំរេចចិត្តថា ការលក់ដីក៏ដូចជាការលក់អនាគតពួកគេផងដែរ ។



តើសហគមន៍របស់អ្នក នឹងធ្វើអ្វី? តើសហគមន៍របស់ អ្នកបានរួបរួមគ្នាដើម្បីអនាគត ឬទេ? តើសហគមន៍របស់អ្នក នឹងធ្វើការគិតគូរយ៉ាងប្រុងប្រយ័ត្នពីជំរើសសំរាប់អនាគត ឬទេ? តើនឹងគិតពីក្មេងជំនាន់ក្រោយឬទេ?

## រឿងនេះបង្កើតឡើងដោយគំរោង CFI សហការជាមួយអង្គការ ICC

### គណៈកម្មការត្រួតពិនិត្យ និងកែសំរួល

ក្រុមការងារថ្នាក់អក្ខរកម្មក្រៅប្រព័ន្ធផ្នែកភាសាគ្រឹង របស់អង្គការសហការ ខេត្តរតនគិរី

---

**គណៈកម្មការត្រួតពិនិត្យ**

លោក : គេង ខាំអយ

លោក : ប៉ាន់ គ្លីម

លោក : គួក កំប្រែង

អ្នកស្រី : ឡាំ ចានី

អ្នកស្រី : ក្លាយ ច្រម៉ច

ដីយើង អនាគតយើង គឺជាប្រភេទសៀវភៅរឿងមួយដែលនិយាយ
អំពីបញ្ហាទំនាស់ដីធ្លី និងជនជាតិភាគតិចនៃប្រទេសកម្ពុជា ។
សៀវភៅនេះផលិតឡើងដើម្បីជាឧបករណ៍មួយសំរាប់បង្កើនការរៀន
អានផង និងសំរាប់ការអប់រំផង ។

**អ្នកនិពន្ធ**

លោក : ប្រ៊្រម ប្រាន

**អ្នករៀបរៀងរឹបច្ចេកទេសកុំព្យូទ័រ**

លោក : ម៉ុន សារឿន

លោក : យ៉េះ ប៉ាទូ

លោក : គីម សាមៀន

**រចនារូបភាពដោយ**

លោក : បាំង កាន់ធឿម


**សំរាប់ព័ត៌មានបន្ថែមអំពីអង្គការសហគមន៍ព្រៃឈើអន្តជាតិ សូមទាក់ទង:**

អង្គការសហគមន៍ព្រៃឈើអន្តជាតិនៅកម្ពុជា

ផ្ទះលេខ ៨១ បេ ផ្លូវលេខ ៥៧ កែងផ្លូវលេខ ៣៩៨. សង្កាត់បឹងកេងកង១

ខ័ណ្ឌចំកាមន ក្រុងភ្នំពេញ កម្ពុជា

ទូរស័ព្ទលេខ : (៨៥៥ ២៣) ២២០ ៧១៤

ទូរសារលេខ : (៨៥៥ ២៣) ២២១ ៦៣៤

អ៊ីម៉ែល : cfioffice@cfi-cambodia.org.kh



This booklet project has been generously funded by the United States Agency for International Development, the John D. & Catherine T. MacArthur Foundation, and International Work Group for Indigenous Affairs. The observations opinions expressed in this publication are those of the authors and do not necessarily reflect any opinion whatever of these donors.



**For further information about CFI, please contact:**

Community Forestry International
# 81b, Street 57, (Corner of St. 398), Sangkat Boeung Keng Kong 1, Khan Charmkar Morn, Phnom Penh, Cambodia
Tel: (855 23) 220 714
Fax: (855 23) 221 634
Email: cfioffice@cfi-cambodia.org.kh



**ឧបត្ថម្ភការបោះពុម្ពដោយ**

International Co-operation Cambodia

International Work Group for Indigenous Affairs

**‘*Our Land Our Future*’ is a series of storybooks about land issues and indigenous peoples in Cambodia. The books are produced as both a literacy and community awareness raising tool.**

## The Story in English - not a direct translation: The Dowm Community

**Page 1:** The Dowm community are facing an uncertain future.
The Dowm community was told that they could sell their land and would be able to get money for development.
The community had a meeting. They thought about what things they needed in order to improve their community.

**Page 2:** After much discussion, they decided on a village meeting hall, health service, education services, money for poor families, and training on agricultural and business skills.

**Page 3:** They thought about the different ways they could get the things they needed to improve their lives. One way was to sell their land. But, they realized that if they sold their land, they would only be able to get income from it one time.

**Page 4:** The community also considered how selling their land might open them to outsiders and possible negative impact on their people. So they thought about ways to use their land so that they could get money to buy the things they wanted.

**Page 5:** They thought of leasing their land to outsiders so that they would pay to use the community land, but they were afraid that they might not get their land back.

**Page 6:** They were also afraid of the possible negative effect of outsiders on their culture and values. So, they thought of other ways of using their land to get the income they needed.

**Page 8:** One thing they thought of was farming the land themselves, selling their crops, and contributing to a community fund.

**Page 10:** They also thought about creating a community plantation. That way, the whole community could contribute a small amount of labor.
The income from the harvest could then be used for the community wish-list.

**Page 12:** Then, they thought about other resources they could use for income. If they protected their land and natural resources then they could collect many products from the forest . For example, they could produce rattan that they could harvest and sell.

**Page 13:** The community could also see that their land, agriculture, forest, community development, and culture might also be assets that others were interested in experiencing. So, they considered that they might learn about tourism so that they could earn income from that.

**Page 14:** They realized that if they preserved their land without selling it, they could keep it clean of chemicals and grow higher-value crops. They also thought that just growing food for themselves would make them happy.

**Page 16:** The community began to realize that by protecting their traditional livelihoods and culture they would be able to grow healthy foods for themselves and for income while being able to pay for much needed services such as better education.

**Page 18:** In the end, the villagers in Dowm village were glad they thought carefully about their future. It is important to remember that there are alternative approaches to development. The Down community decided that selling land is like selling their future

**Page 19:** What will your community do? Will your community work together? Will your community think carefully about the options for the future?
Will your community think for future generations?